**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**
**អគ្គនាយកដ្ឋានយោធសេវា**
**នាយកដ្ឋានព័ត៌មាន**
លេខ:.................

# សេចក្តីប្រកាសព័ត៌មាន

តបតាមការអញ្ជើញរបស់ក្រសួងការពារជាតិ នៃព្រះរាជាណាចក្រកម្ពុជា គណៈប្រតិភូយោធាជាន់ខ្ពស់ក្រសួងការពារប្រទេសនៃសាធារណរដ្ឋសង្គមនិយមវៀតណាមដឹកនាំដោយ **ឯកឧត្តម ឧត្តមសេនីយ៍ឯកបម្រុង ង្វៀន ជីវិញ** សមាជិកមជ្ឈឹមបក្ស និងជាអនុរដ្ឋមន្ត្រី ក្រសួងការពារប្រទេសវៀតណាម នឹងអញ្ជើញមកបំពេញទស្សនកិច្ចការងារនៅព្រះរាជាណាចក្រកម្ពុជា ពីថ្ងៃទី ២០ ដល់ថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ២០១៧ ។

ក្នុងអំឡុងពេលបំពេញទស្សនកិច្ចផ្លូវការនេះ **ឯកឧត្តម ឧត្តមសេនីយ៍ឯកបម្រុង ង្វៀន ជីវិញ** ព្រមទាំងសហការី នឹងអញ្ជើញចូលរួមក្នុងកិច្ចសន្ទនានយោបាយការពារជាតិ ថ្នាក់អនុរដ្ឋមន្ត្រី **កម្ពុជា-វៀតណាម** លើកទី៣ ជាមួយ **ឯកឧត្តម នាយឧត្តមសេនីយ៍ នាង ផាត** រដ្ឋលេខាធិការក្រសួងការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា។

គោលបំណងនៃកិច្ចសន្ទនានយោបាយការពារជាតិ **កម្ពុជា - វៀតណាម** គឺជំរុញអោយមានកិច្ចសហប្រតិបត្តិការល្អ លើគ្រប់វិស័យ ទាំងការពង្រឹង និងពង្រីកទំនាក់ទំនងមិត្តភាព សាមគ្គីភាព ដែលបានអនុវត្តយ៉ាងត្រឹមត្រូវ និងមានប្រសិទ្ធិភាពនាពេលកន្លងមក ជាពិសេសភាគីទាំងពីរ នឹងបន្តអនុវត្តឲ្យបានល្អប្រសើរបន្ថែមទៀតនូវអនុស្សារណៈ និងពិធីសារ ស្តីពីកិច្ចសហប្រតិបត្តិការ ការពារជាតិទ្វេភាគី រវាងក្រសួងការពារជាតិ នៃប្រទេសយើងទាំងពីរ **កម្ពុជា - វៀតណាម** នាពេលខាងមុខ។

ក្នុងដំណើរទស្សនកិច្ចនេះ គណៈប្រតិភូក៏មានកិត្តិយសនឹងអញ្ជើញចូលជួបសម្តែងការគួរសម ជាមួយ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និង**សម្តេចពិជ័យសេនា ទៀ បាញ់ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ** ផងដែរ ។

ថ្ងៃអង្គារ ២កើត ខែបុស្ស ឆ្នាំរកា ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៧